ធនធានគាំទ្រឲ្យពុក ឬម្តាយ

ធនធានគាំទ្រឲ្យពុក ឬម្តាយ អាចជាឧបករណមួយដើម្បីជួយដល់បណ្តាគ្រួសារ។ ធនធានទាំងនេះអាចជាវិធីដ៏អស្ចារ្យមួយដើម្បីបំពេញឲ្យពុកម្តាយដទៃ ឱ្យកូនៗរបស់អ្នកលេខជាមួយអ្នកដទៃ សិក្សាពីជំនាញថ្មីៗ ឬភ្ជាប់អ្នកទៅកាន់អ្នកអប់រំដែលអាចជួយអ្នកដោះស្រាយការប្រឈមទាំងឡាយ។

WithinReach ទទួលស្គាល់ថា គ្រួសារនីមួយៗគឺប្លែកពីគេ។ បុគ្គលិក WithinReach ទន្ទឹងរង់ចាំពិភាក្សាជាមួយអ្នក និងធ្វើការជាមួយគ្នាដើម្បីស្វែងរកធនធានទានាដែលជាការផ្គផ្គងល្អបំផុតសម្រាប់គ្រួសាររបស់អ្នក។

WASHINGTON WorkFirst

WithinReach™

Washington State Department of Social & Health Services

Transforming lives

DSHS 22-1780 CA (12/18) Cambodian

សេវាកម្មនានាសម្រាប់ បណ្តាគ្រួសារមកពី WithinReach™

ការចិញ្ចឹមកូនៗដ៏ល្អបំផុត

DSHS តំបន់ 2 WorkFirst

ជាដៃគូជាមួយ

WithinReach™

Washington State Department of Social & Health Services

Transforming lives

WithinReach™

តើ WithinReach ជានរណា?

គឺជាអង្គភាពមិនដើម្បីប្រាក់ចំណេញមួយដែលផ្តួយដល់បណ្តាគ្រួសាររុករកសុខភាពស្មុគ្រស្មាញ និងប្រព័ន្ធសេវាកម្មសង្គម។ អ្នកអាចសិក្សាបន្ថែមអំពី WithinReach នៅ www.withinreachwa.org

តើ WithinReach ធ្វើអ្វីខ្លះ?

បុគ្គលិក WithinReach នឹងធ្វើការជាមួយគ្រួសាររបស់អ្នកដើម្បីស្វែងរកធនធានឪពុក ឬម្តាយដែលបំពេញបានតាមសេចក្តីត្រូវការរបស់អ្នក។ អត្ថប្រយោជន៍ខ្លះនៃការធ្វើការជាមួយ WithinReach ៖

- ការប្រាស្រ័យទាក់ទងងាយស្រួលជាមួយបុគ្គលិក
- អ្នកកំណត់អត្តសញ្ញាណអាទិភាពរបស់អ្នក
- បុគ្គលិកចំណាយពេលដើម្បីយល់ពីសេចក្តីត្រូវការរបស់បុគ្គលម្នាក់។
- ការស្វែងរកដែលបានរៀបចំទុកសម្រាប់ធនធានទានៅផ្អែកលើសេចក្តីត្រូវការទីតាំង និងមធ្យោបាយដឹកជញ្ជូន
- បុគ្គលិកមានចំណេះដឹងជ្រាលជ្រៅអំពីភាពមានសិទ្ធិទទួល និងតម្រូវការនៃការចុះឈ្មោះ
- ការបញ្ជូនទានៅផ្អែកលើសេចក្តីត្រូវការរបស់អ្នក
- មូលដ្ឋានទិន្នន័យធនធានគឺត្រូវបានធ្វើបច្ចុប្បន្នភាពជារៀងទាត់

តើធនធានអ្វីខ្លះគឺអាចរកបាន?

ធនធានគាំទ្រឪពុក ឬម្តាយខុសគ្នាផ្អែកលើសេចក្តីត្រូវការរបស់គ្រួសារអ្នក។ WithinReach មានធនធានទានាសម្រាប់ស្ត្រីមានផ្ទៃពោះ និងឪពុកម្តាយនៃកុមារវ័យក្មេង។ បុគ្គលិកប្រឹងប្រែងអស់ពីសមត្ថភាពរបស់ពួកគេដើម្បីស្វែងរកធនធានទានាដែលបំពេញបានតាមអាទិភាពរបស់គ្រួសារអ្នក។ ធនធានទានាដែលមានគឺអាចខុសគ្នាអាស្រ័យលើស្ថានភាពគ្រួសាររបស់អ្នក ក្ងដហ្ស៊ីប និងអាយុកូនរបស់អ្នក។

ឧទាហរណ៍នៃធនធានគាំទ្រឪពុក ឬម្តាយ៖
ថ្នាក់កំណើតកុមារ
ថ្នាក់អប់រំឪពុក ឬម្តាយ
ក្រុមលេង និងសិក្សា
គ្រឿងផ្គត់ផ្គង់ភាពមានផ្ទៃពោះ និងទារក
សេវាកម្ម Doula
កម្មវិធីគាំទ្រឪពុក ឬម្តាយនៅផ្ទះ៖ Early Head Start, ឪពុកម្តាយជាគ្រូបង្រៀន, ភាពជាដៃគូគ្រួសារគិលានុបដ្ឋាយិកា, កម្មវិធី Doula ថែទាំអ្នកជំងឺតាមមូលដ្ឋាន Open Arms, ជាដើម។
ក្រុមគាំទ្រឪពុក ឬម្តាយថ្មី
កម្មវិធី Head Start/ECEAP

តើអ្នកអាចរំពឹងអ្វីខ្លះ?

1. បុគ្គលិក WorkFirst នឹងផ្ញើការបញ្ជូនមួយទៅ WithinReach សម្រាប់អ្នក
2. WithinReach នឹងស្រាវជ្រាវកម្មវិធីទានាក្នុងតំបន់របស់អ្នក
3. WithinReach នឹងហៅទូរស័ព្ទ ផ្ញើសារ ឬផ្ញើអ៊ីម៉ែលទៅអ្នក
   - បុគ្គលិកនឹងធ្វើពីរបីការប៉ុនប៉ងដើម្បីភ្ជាប់ជាមួយគ្រួសាររបស់អ្នក
   - ពួកគេនឹងទុកសារជាសំឡេងមួយ បើពួកគេមិនអាចឈានរកអ្នកបាន
4. WithinReach នឹងស្តាប់ក្តីកង្វល់ និងអាទិភាពទានារបស់អ្នក
5. WithinReach នឹងផ្ទូផ្ទងអ្នកជាមួយធនធានទានាដែលស័ក្តិសមល្អបំផុតនឹងសេចក្តីត្រូវការរបស់អ្នក
6. WithinReach នឹងផ្តល់ឱ្យអ្នកនូវបញ្ជីធនធានដែលបានពិភាក្សារួច
7. WithinReach នឹងធ្វើការភ្ជាប់ទំនាក់ទំនងទៅកាន់ធនធាន/កម្មវិធីសហគមន៍ នៅពេលអាច

www.withinreachwa.org